ទីតាំងសម្អាតនៅ Industrial Container Services WA LLC



7152 1st Ave. S., Seattle, King County.

មតិយោបល់ដែលបានទទួលយកពី៖

ថ្ងៃទី 18 ខែវិច្ឆិកា ឆ្នាំ 2024 (ម៉ោង 12:00 ព្រឹក) – ថ្ងៃទី 16 ខែមករា ឆ្នាំ 2025 (ម៉ោង 11:59 យប់)

ដាក់បញ្ជូនមតិយោបល់៖

តាមអនឡាញ៖
https://go.ecology.wa.gov/ics_comment

តាមប្រៃសណីយ៍៖
Beau Johnson, Site Manager
PO Box 330316
Shoreline, WA 98133-9716
(206) 638-0816
beau.johnson@ecy.wa.gov

ការពិនិត្យឯកសារ៖

https://go.ecology.wa.gov/ICS

Seattle Public Library
South Park Branch
8604 8th Ave S., Seattle, WA

ព័ត៌មានអំពីការដ្ឋាន៖

លេខសម្គាល់ទីតាំងការដ្ឋាន៖ 2154
លេខសម្គាល់នៃការសម្អាតទីតាំង៖ 62

ទំនាក់ទំនងផ្សព្វផ្សាយសាធារណៈ៖

Meredith Waldref
អ្នករៀបចំផែនការផ្សព្វផ្សាយ
meredith.waldref@ecy.wa.gov
(425) 229-3683

ឯកសារត្រៀមរួចរាល់ដើម្បីពិនិត្យ និងផ្តល់មតិយោបល់ជាសាធារណៈ:

ក្រសួង Ecology អញ្ជើញអ្នកឱ្យផ្តល់មតិយោបល់លើឯកសារជាច្រើនសម្រាប់ទីតាំងសម្អាត Industrial Container Services WA LLC (Site) ដែលមានទីតាំងនៅ 7152 1st Ave. S. ក្នុងទីក្រុង Seattle ជិតសង្កាត់ Seattle's South Park Neighborhood និងស្ពាន First Ave. South ឆ្លងទន្លេ Lower Duwamish Waterway។

ឯកសារខាងក្រោមអាចរកបាន៖

- ការស៊ើបអង្កេតអំពីដំណោះស្រាយ៖ ឯកសារដែលរៀបរាប់លម្អិតអំពីលក្ខណៈ (ប្រភេទ) និងវិសាលភាព (ទីតាំង) នៃការបំពុលនៅនឹងទីតាំងនោះ។
- ការសិក្សាអំពីលទ្ធភាពបំពេញការងារ៖ ឯកសារដែលបង្ហាញពីវិធីសាស្ត្រសម្អាតផ្សេងៗគ្នា ដែលហៅថាជម្រើសជំនួស។ ឯកសារនេះរួមបញ្ចូលនូវជម្រើសជំនួសដែលពេញចិត្តរបស់ក្រសួង Ecology។

មានសំណួរដែរឬទេ?
ចូលរួមជាមួយយើងខ្ញុំនៅម៉ោងធ្វើការក្នុងសហគមន៍របស់យើង!

សូមចូលរួមជាមួយយើងខ្ញុំនៅក្នុងខែនេះនៅ South Park ដើម្បីស្វែងយល់បន្ថែមអំពីទីតាំងសម្អាតនេះ និងកន្លែងផ្សេងទៀតនៅតាមបណ្តោយ Lower Duwamish Waterway។ សេវាបកប្រែផ្តល់មាត់តាមទូរសព្ទ អាចរកបានជាភាសាអេស្ប៉ាញ ភាសាចិន ភាសាវៀតណាម និងភាសាខ្មែរ។ ស្វាគមន៍មនុស្សគ្រប់រឿយ!

ថ្ងៃពុធ ទី 20 ខែវិច្ឆិកា ឆ្នាំ 2024
(ម៉ោង 4:00 ល្ងាច – 6:00 ល្ងាច)


ទីតាំង៖ Seattle Public Library
South Park Branch
8604 8th Ave S., Seattle, WA
(206) 615-1688

ស្កែនរក
ព័ត៌មានចុងក្រោយបំផុតអំពីទន្លេ Lower Duwamish Waterway

សម្រាប់ព័ត៌មានអំពីភាសាបន្ថែម សូមមើលទំព័រទី 5 →

ទីតាំងនៅផ្នែកខាងក្រោយ

ទីតាំងនេះស្ថិតនៅក្នុងតំបន់ឧស្សាហកម្មនៃទីក្រុង Seattle នៅត្រើយខាងលិចនៃទន្លេ Lower Duwamish Waterway (LDW)។ ក្នុងឆ្នាំ 2010 ក្រសួង Ecology បានចរចារកិច្ចព្រមព្រៀងផ្លូវច្បាប់មួយ ដែលហៅថាបទបញ្ជាដែលបានព្រមព្រៀង (Agreed Order) ជាមួយម្ចាស់អចលនទ្រព្យ Herman Trotsky និងប្រតិបត្តិករនៅទីតាំង Industrial Container Services-WA, LLC ដែលជាអ្នកទទួលខុសត្រូវជាសក្តានុពល (Potentially Liable Persons, PLP) សម្រាប់ទីតាំងនេះ។



ព្រំដែនភាគខាងជើងជាប់ ជាមួយនឹងទីតាំងសម្អាតនៅផែ Douglas Management Dock[1]។ ទីតាំង នេះមានច្រកចូលទៅកាន់ទន្លេ Duwamish River (ដែទន្លេ Trotsky) នៅភាគខាងជើង។

សកម្មភាពឧស្សាហកម្មនៅនឹងទីតាំងបានកើតឡើងនៅពេលវេលាបន្ទាប់៖

- **ទសវត្សរ៍ឆ្នាំ 1930៖** ប្រតិបត្តិការរៀបចំឡើងវិញ និងផលិតធុងរាងស៊ីឡាំងដំបូងបំផុតបានធ្វើឡើងនៅទីតាំងនោះ។
- **ទសវត្សរ៍ឆ្នាំ 1940៖** ក្រុមហ៊ុន Mitzel & Co. ត្រូវបានគេរាយការណ៍ថាបានយកប្រើធុងរាងស៊ីឡាំងជាថ្មីចំនួន 1,500 ធុងក្នុងមួយខែសម្រាប់រដ្ឋាភិបាលសហរដ្ឋអាមេរិកក្នុងអំឡុងពេលសង្គ្រាមលោកលើកទី II។
- **ឆ្នាំ 1953៖** ក្រុមគ្រួសារ Trotsky បានទិញទីតាំងនេះ ហើយបានដំណើរការទីតាំងនេះជា Northwest Cooperage។
- **1973-1990៖** អចលនទ្រព្យត្រូវបានរុះរើ និងក្រាលការ៉ូឡាឬបេតុង ហើយប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំណល់ជាមុនត្រូវបានដំឡើង។ ប្រព័ន្ធប្រព្រឹត្តិកម្មទឹកជាមុនរួមមានប្រព័ន្ធលូ "បិទជិត" ដែលបង្ហូរទឹកទាំងអស់ រួមទាំងទឹកភ្ជុះភ្លៀង ទឹកហៀរ និងទឹកដែលបានធ្វើប្រព្រឹត្តិកម្មហើយ ទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំណល់ជាមុនដែលហូរចូលទៅក្នុងលូទឹកស្អាត។
- **ថ្ងៃនេះ៖** Industrial Container Services-WA, LLC បច្ចុប្បន្នជួលអចលនទ្រព្យ និងបន្តដំណើរការរោងចក្ររៀបចំធុងស៊ីឡាំងឡើងវិញ។ ប្រតិបត្តិការនៅទីតាំងនោះរួមមាន ការក្សាទុក ការសម្អាត និងការលាបថ្នាំធុងស៊ីឡាំងដែលបានប្រើហើយឡើងវិញ ដែលខ្លះអាចមានផលិតផលមួយអាហារ ផលិតផលប្រេងឥន្ធនៈ សារធាតុរំលាយ ជ័រ ថ្នាំលាប ការ ឬវត្ថុធាតុផ្សេងទៀត។

ការស៊ើបអង្កេតអំពីការបំពុល (ការស៊ើបអង្កេតអំពីដំណោះស្រាយ)

ការស៊ើបអង្កេតបានរកឃើញការចម្លងរោគដូចខាងក្រោមលើសពីកម្រិតសម្អាតនៃរដ្ឋ WA៖

- **ដី៖** លោហធាតុ អ៊ីដ្រូកាបូនប្រេងឥន្ធនៈ៖ អ៊ីដ្រូកាបូនអារ៉ូម៉ាទិចប៉ូលីស៊ីគ្លិចដែលបង្កជំងឺមហារីក (carcinogenic polycyclic aromatic hydrocarbons, cPAH) សារធាតុគីមី pentachlorophenol (PCP) ថ្នាំសម្លាប់សត្វល្អិត DDT សារធាតុគីមី dieldrin សារធាតុគីមីសរីរាង្គ polychlorinated biphenyls (PCB) សមាសធាតុសរីរាង្គដែលងាយនឹងបង្កគ្រោះថ្នាក់ (volatile organic compounds, VOC)។
- **ទឹកក្រោមដី៖** VOC, សមាសធាតុសរីរាង្គដែលងាយនឹងបង្កគ្រោះថ្នាក់មធ្យម (semivolatile organic compounds, SVOC), PCB អ៊ីដ្រូកាបូនប្រេងឥន្ធនៈ និងថ្នាំសម្លាប់សត្វល្អិត
- **ឥតកែរ៖** PCB លោហធាតុ និង SVOC

ពិចារណាជម្រើស (ការសិក្សាអំពីលទ្ធភាព)


PLPS បានរៀបចំការសិក្សាអំពីលទ្ធភាពដើម្បីដោះស្រាយការបំពុល ដែលបានរកឃើញនៅទីតាំងនោះ។ ការសិក្សាអំពីលទ្ធភាពបានវាយតម្លៃជម្រើសសម្អាតជំនួសចំនួនប្រាំពីរផ្សេងគ្នា។ បន្ទាប់មកថ្លៃចំណាយ និងអត្ថប្រយោជន៍ចំពោះបរិស្ថាននៃជម្រើសជំនួសត្រូវបានយកមកប្រៀបធៀប ដែលនាំឱ្យមានជម្រើសសម្អាតជំនួសដែលពេញចិត្តមួយ។

[1] https://apps.ecology.wa.gov/gsp/Sitepage.aspx?csid=6967

កម្មវិធីសម្អាតសារជាតិពុល

ជម្រើសសម្អាតជំនួសនៅតំបន់ខ្ពង់រាប៖

- **តំបន់ខ្ពង់រាបជាជម្រើសជំនួសទី 1៖**
  ការទប់ស្កាត់សារជាតុកខ្វក់
  ការជីកយកសារជាតុរាវដែលមិនរលាយក្នុងទឹក (Light Non-Aqueous Phase Liquid, LNAPL)
  និងការពិនិត្យតាមដាន
- **តំបន់ខ្ពង់រាបជាជម្រើសជំនួសទី 2៖**
  ការទប់ស្កាត់សារជាតុកខ្វក់ ការជីកយកសារជាតុ LNAPL និងការជីកដីផ្ទៃខាងលើ
  (ដោយមានរបាំងការពារ)
- **តំបន់ខ្ពង់រាបជាជម្រើសជំនួសទី 3៖**
  ការទប់ស្កាត់សារជាតុកខ្វក់ ការជីកយកសារជាតុ LNAPL និងការជីកដីផ្ទៃខាងលើ
  (ដោយមិនមានរបាំងការពារ)
- **តំបន់ខ្ពង់រាបជាជម្រើសជំនួសទី 4៖**
  ការទប់ស្កាត់សារជាតុកខ្វក់ ការជីកយកសារជាតុ LNAPL ការជីកយកដីផ្ទៃខាងលើ
  (ដោយគ្មានរបាំងការពារ)
  និងការជីកយកដីល្បាប់ពីបឹងពីមុន



ទីតាំងប្រហាក់ប្រហែលនៃតំបន់សម្អាតទាំងបួនត្រូវបានលើកឡើងនៅក្នុងការសិក្សាអំពីលទ្ធភាព។

ជម្រើសខាងកើតនៃរោងចក្រកែច្នៃធុងស៊ីឡាំង (តំបន់ ED)៖

- **ED ជាជម្រើសជំនួសទី 1៖** ការត្រួតពិនិត្យ
- **ED ជាជម្រើសជំនួសទី 2៖** ការត្រួតពិនិត្យ និងការបំភាយខ្យល់/ការទាញយកសារជាតុកខ្វក់ចេញពីដី
- **ED ជាជម្រើសជំនួសទី 3៖** ការពិនិត្យ និងដំណើរការធ្វើប្រព្រឹត្តកម្មនៅនឹងកន្លែង

ការសម្អាតក្នុងទឹក (តំបន់ឆកទន្លេ)៖

Lower Duwamish Waterway Group (LDWG) នឹងធ្វើការសម្អាតតំបន់ឆកទន្លេ (តំបន់ឆ្នេរដែលបង្កើតបានជាដៃទន្លេ) ក្នុងអំឡុងពេលការងារសម្អាត superfund ដែលត្រួតពិនិត្យដោយទីភ្នាក់ងារ Environmental Protection Agency (EPA)។ ជម្រើសដែលពេញចិត្តត្រូវបានជ្រើសរើសដោយ EPA ដោយផ្អែកលើទិន្នន័យសង្ខេបនៅក្នុងឯកសារ Lower Duwmaish Waterway Feasibility Study (AECOM 2021)[2] និង Lower Duwamish Waterway Record of Decision (USEPA 2014)[3]

ជម្រើសសម្អាតដែលពេញចិត្ត៖

ការរួមបញ្ចូលជម្រើសតំបន់ខ្ពង់រាបទី 3 និងទី 4 ជម្រើសតំបន់ ED ទី 1 និងជម្រើសក្នុងទឹកដែលបានជ្រើសរើសដោយ EPA មានសកម្មភាពដូចខាងក្រោម ដែលត្រូវបានពន្យល់យ៉ាងលម្អិតជាងនេះ៖

តំបន់ខ្ពង់រាបជាជម្រើសទី 3 និងទី 4៖

- **ការជីក៖** ដីដែលរងការបំពុលនឹងត្រូវយកចេញនៅកន្លែងជាច្រើននៅនឹងកន្លែងសម្អាត។ សារជាតុទាំងអស់នឹងត្រូវបានបោះចោលនៅកន្លែងដែលមានបទប្បញ្ញត្តិគ្រប់គ្រងយោងតាមកំហាប់ PCB និងការអនុម័តរបស់ EPA។
  - *តំបន់ឆ្នេរខាងក្បែរនៃឆកទន្លេ៖* NAPL ដែលផ្លាស់ទី (សារជាតុកខ្វក់រាវ) ពីអណ្តូងត្រួតពិនិត្យទី 1 រួមជាមួយនឹងដីកខ្វក់ពីពីរទៅប្រាំបីហ្វីតនៅតាមបណ្តោយឆ្នេរខាងក្បែរនឹងត្រូវបានយកចេញ។ នេះនឹងបង្កើតប្រាំងចំណោតស្ថិរភាពដែលនឹងភ្ជាប់ជាមួយនឹងការសម្អាតតំបន់ឆកទន្លេ ដែលធ្វើឡើងដោយ EPA។ រុក្ខជាតិនៅតំបន់ជាប់ទន្លេ (មាត់ទន្លេ) នឹងត្រូវបានដាំដុះនៅតាមបណ្តោយឆ្នេរខាងក្បែរជាថ្មី។

[2] https://ldwg.org/wp-content/uploads/2019/01/LDW-Final-FS-Executive-Summary_October-31-2012_ADA.pdf
[3] https://semspub.epa.gov/work/10/715975.pdf

- *បន្ទាត់អចលនទ្រព្យប៉ែកខាងកើត៖* សារធាតុបំពុលដែលកប់ក្នុងបឹងនឹងត្រូវបានយកចេញ ហើយចាក់បំពេញវិញដោយខ្សាច់ និងក្រួសពីកន្លែងផ្សេង។ សារធាតុដែលបានចាក់បំពេញនៅខាងក្រោមទឹកនឹងត្រូវលាយជាមួយនឹងកាបូនសរីរាង្គ 0.5%។

- **ការដំឡើងគម្រប៖** ចិញ្ចើមផ្លូវនៅទីតាំងនោះនឹងត្រូវថែទាំ ឬជួសជុលដើម្បីផ្តល់របាំងការពារ ដែលហៅថាគម្រប ដើម្បីការពារការប៉ះពាល់របស់មនុស្សជាមួយដី និងទឹកក្រោមដីដែលមានការបំពុល។ គម្របក៏នឹងកំណត់បរិមាណទឹកភ្លៀងពីការជ្រាបចូលទៅក្នុងដី និងលាយជាមួយនឹងសារធាតុបំពុលផងដែរ។
- **ការតាមដានទឹកក្រោមដីរយៈពេលវែង៖** ទឹកក្រោមដីនឹងត្រូវបានត្រួតពិនិត្យដើម្បីប្រាកដថាសកម្មភាពតាមមាត់ផ្លូវ និងសម្អាតនៅទីតាំងបន្តការពារទន្លេ LDW។
- **ការគ្រប់គ្រងរបស់ស្ថាប័ន៖** វិធានការច្បាប់ ឬរដ្ឋបាលនឹងត្រូវដាក់ឱ្យអនុវត្តដើម្បីរឹតបន្តឹង ឬហាមឃាត់សកម្មភាពដែលអាចបណ្តាលឱ្យមានការប៉ះពាល់ទៅនឹងការបំពុល ដែលលើសពីកម្រិតហានិភ័យសុខភាពដែលអាចទទួលយកបាន ឬបង្អាក់ដល់ស្ថិរភាពនៃសកម្មភាពសម្អាត។
- ទឹកភ្លៀងព្យុះដែលហូរនឹងបន្តប្រមូលផ្តុំ និងធ្វើប្រព្រឹត្តកម្ម (ប្រសិនបើចាំបាច់) ជាផ្នែកមួយនៃប្រតិបត្តិការរបស់ Industrial Container Services។

តំបន់ ED ជាជម្រើសទី 1

- កម្មវិធីត្រួតពិនិត្យនឹងត្រូវបង្កើតឡើងដើម្បីធា ជានូវស្ថានភាពល្អនៃគម្របតាមមាត់ផ្លូវថ្នល់នៅក្នុងតំបន់នេះ។ ការត្រួតពិនិត្យទឹកក្រោមដីរយៈពេលវែងនឹងធ្វើឡើង។

ជម្រើសក្នុងទឹកដែលបានជ្រើសរើស EPA

EPA មិនទាន់បានជ្រើសរើសសកម្មភាពសម្អាតសម្រាប់ច្រកចូលនៅឡើយទេ។ សកម្មភាពសម្អាតមួយចំនួនដែលត្រូវបានចាត់ទុកថាមានដូចជា ការបូមខ្សាច់ ការគ្រប និងការតាមដានការថយចុះនៃធម្មជាតិ។

ហេតុអ្វីបានជាទីតាំងនេះមានសារៈសំខាន់

ទីតាំងនេះស្ថិតនៅតាមបណ្តោ យផ្លូវទឹក Lower Duwamish Waterway[4] Superfund Site ដែលមានប្រវែង 5 ម៉ាយល៍ពីទន្លេ Duwamish River។ ទីភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency, EPA) សហរដ្ឋអាមេរិកបានបន្ថែមទីតាំង LDW Superfund Site[5] ទៅក្នុងបញ្ជីអាទិភាពជាតិរបស់ Superfund នៅក្នុងឆ្នាំ 2001។ ក្រសួង Ecology កំពុងធ្វើការដើម្បីបញ្ឈប់ ឬកាត់បន្ថយប្រភពបំពុលទៅកាន់ការដ្ឋាន LDW Superfund Site ជាការខិតខំប្រឹងប្រែងដែលស្គាល់ថាជា "ការគ្រប់គ្រងប្រភព[6]" ដើម្បីឱ្យ EPA អាចបន្តការសម្អាតដ៏ល្បាប់ក្នុងទន្លេបាន។ កន្លែងសម្អាតនេះមានទីតាំងស្ថិតនៅចំកណ្តាលនៅទន្លេ 2.1-2.2 ម៉ាយល៍ខាងលិច៖ ដៃទន្លេ Trotsky[7]។

[4] https://ecology.wa.gov/Spills-Cleanup/Contamination-cleanup/Cleanup-sites/Lower-Duwamish-Waterway
[5] https://cumulis.epa.gov/supercpad/cursites/csitinfo.cfm?id=1002020
[6] https://ecology.wa.gov/Spills-Cleanup/Contamination-cleanup/Cleanup-sites/Lower-Duwamish-Waterway/Source-control
[7] https://ecology.wa.gov/spills-cleanup/contamination-cleanup/cleanup-sites/lower-duwamish-waterway/source-control/source-control-areas

តើអ្វីនឹងកើតឡើងបន្ទាប់?

ក្រសួង Ecology នឹងពិចារណារាល់មតិយោបល់ដែលទទួលបានក្នុងអំឡុងពេលនៃការផ្តល់មតិយោបល់ជាសាធារណៈនេះ ហើយអាចធ្វើការផ្លាស់ប្តូរឯកសារ។ ប្រសិនបើឯកសារតម្រូវឱ្យមានការផ្លាស់ប្តូរសំខាន់ៗ យើងនឹងមានរយៈពេលនៃការផ្តល់មតិយោបល់ជាសាធារណៈមួយផ្សេងទៀត។ ប្រសិនបើមិនមានការផ្លាស់ប្តូរត្រូវឱ្យកត់សម្គាល់ទេ ក្រសួង Ecology ហើយបន្ទាប់មក PLP នឹងបញ្ចប់ឯកសារនេះ។ ផែនការសកម្មភាពសម្អាត និងកិច្ចព្រមព្រៀងផ្លូវច្បាប់នាពេលអនាគតនឹងមានសម្រាប់ការពិនិត្យឡើងវិញក្នុងអំឡុងពេលផ្តល់យោបល់នាពេលអនាគត។

ដំណើរការសម្អាតរបស់ក្រសួង Ecology

ច្បាប់ស្តីពីការគ្រប់គ្រងសារជាតិពុលគំរូ (Model Toxics Control Act, MTCA[8])គឺជាបទបញ្ញត្តិស្តីពីការសម្អាតបរិស្ថានរបស់រដ្ឋ Washington។ ច្បាប់នេះផ្តល់លក្ខខណ្ឌតម្រូវសម្រាប់ការសម្អាតទីតាំងដែលមានការបំពុល និងកំណត់ស្តង់ដាដែលការពារសុខភាពមនុស្ស និងបរិស្ថាន។ ក្រសួង Ecology ទទួលខុសត្រូវក្នុងការគ្រប់គ្រង MTCA រួមទាំងការត្រួតពិនិត្យការសម្អាត។ ដំណើរការសម្អាតរបស់ MTCA[9] ត្រូវបញ្ចប់ជាជំហានៗ (សូមមើលក្រាហ្វិកខាងក្រោម) តាមបន្ទាត់ពេលវេលាដែលប្រែប្រួលមួយ។

ឯកសារពិនិត្យឡើងវិញរបស់ទីតាំងនេះត្រូវបានរៀបរាប់ខាងក្រោមដោយពណ៌ក្រហម។



ដំណើរការសម្អាតជាផ្លូវការរបស់រដ្ឋ Washington

ព័ត៌មានអំពីភាសា

Español: Si desea obtener una copia de esta información en español, visite nuestra página web (https://go.ecology.wa.gov/ICS) o comuníquese con el Seattle Public Library's South Park Branch (8604 8th Ave S. Seattle) por teléfono al (360) 742-1554 o por correo electrónico a preguntas@ecy.wa.gov.

中文: 您可以访问我们的网站查看这条信息的中文版本(https://go.ecology.wa.gov/ICS)，或前往位于 8604 8th Ave S. Seattle 的西雅图公共图书馆南公园分馆(Seattle Public Library South Park Branch)，也可致电 (425) 229-3683，或发送电子邮件至sunny.becker@ecy.wa.gov.

Tiếng Việt: Quý vị có thể xem bản sao thông tin này bằng Tiếng Việt bằng cách truy cập trang web của chúng tôi (https://go.ecology.wa.gov/ICS) hoặc ghé thăm Chi Nhánh South Park của Thư Viện Công Cộng Seattle (Seattle Public Library) (8604 8th Ave S. Seattle), gọi số (360) 790-4730 hoặc gửi email đến địa chỉ lngu461@ecy.wa.gov.

ភាសាខ្មែរ:
អ្នកអាចមើលច្បាប់ចម្លងនៃព័ត៌មាននេះជាភាសាខ្មែរដោយចូលមើលគេហទំព័ររបស់យើង (https://go.ecology.wa.gov/ICS) ឬមកកាន់សាខា South Park Branch របស់ Seattle Public Library (8604 8th Ave S. Seattle) ទូរស័ព្ទមកលេខ (425) 229-3683 ឬអ៊ីមែលទៅកាន់ meredith.waldref@ecy.wa.gov។

[8] https://ecology.wa.gov/mtca
[9] https://ecology.wa.gov/Spills-Cleanup/Contamination-cleanup/Cleanup-process
[6] https://apps.ecology.wa.gov/publications/SummaryPages/1909166.html

DEPARTMENT OF ECOLOGY
State of Washington

Toxics Cleanup Program
PO Box 330316
Shoreline, WA 98133-9716

ទីតាំងសម្អាតនៅ Industrial Container Services WA LLC
ឯកសារត្រៀមរួចរាល់ដើម្បីពិនិត្យ និងផ្តល់មតិយោបល់ជាសាធារណៈ

DEPARTMENT OF ECOLOGY
State of Washington

Información en Español incluida (página 5)
有關的信息, 已被翻譯成中文（第5頁)
Có thông tin bằng tiếng Việt (Trang 5)
ព័ត៌មានជាភាសាខ្មែររួមបញ្ចូល (ទំព័រ 5)

រយៈពេលសម្រាប់ការផ្តល់មតិយោបល់ជាសាធារណៈ:
ថ្ងៃទី 18 ខែវិច្ឆិកា ឆ្នាំ 2024 (ម៉ោង 12:00 ព្រឹក) – ថ្ងៃទី 16 ខែមករា ឆ្នាំ 2025 (ម៉ោង 11:59 យប់)
https://go.ecology.wa.gov/ICS

ព្រឹត្តិការណ៍សាធារណៈ – សូមមើលទំព័រទី 1 សម្រាប់ព័ត៌មាន
ថ្ងៃពុធ ទី 20 ខែវិច្ឆិកា ឆ្នាំ 2024 ម៉ោង 4:00 ល្ងាច - 6:00 ល្ងាច
Seattle Public Library – South Park Branch
ស្វាគមន៍មនុស្សគ្រប់វ័យ!



ផែនទីពីលើអាកាសនៃទីតាំងសម្អាត Industrial Container Services WA LLC

លទ្ធភាពចូលប្រើប្រាស់ស្តីពីជនពិការអាមេរិក (Americans with Disabilities Act, ADA)
ដើម្បីស្នើសុំការសម្របសម្រួលពី ADA សូមទាក់ទងក្រសួង Ecology តាមទូរសព្ទលេខ 425-229-3683 ឬអ៊ីមែល LDW@ecy.wa.gov ឬចូលមើលគេហទំព័រ ecology.wa.gov/Accessibility ។ សម្រាប់សេវាបញ្ជូនបន្ត ឬ TTY សូមទូរសព្ទទៅលេខ 711 ឬ 877-833-6341។